Washington State Department of Social & Health Services

ការអនុញ្ញាតសំណងជំនួយអន្តរកាល
ការបង់ប្រាក់ដំបូង
INITIAL PAYMENT

ឈ្មោះសំណុំរឿង	អត្តលេខសន្តិសុខសង្គម	អត្តលេខអតិថិជន	លេខទូរស័ព្ទ

អាស័យដ្ឋានតាមឈ្មោះផ្លូវ	ទីក្រុង	រដ្ឋ	លេខស៊ីបកូដ
អាស័យដ្ឋានផ្ញើសំបុត្រ	ទីក្រុង	រដ្ឋ	លេខស៊ីបកូដ

ពាក្យថា រដ្ឋ មានន័យឬសំដៅយកក្រសួងសង្គមកិច្ច និងសុខាភិបាល ។

តើខ្ញុំអនុញ្ញាតឱយរដ្ឋធ្វើអ្វីខ្លះ ដោយចុះហត្ថលេខាលើក្រដាសពាក្យអនុញ្ញាតនេះ?

បើគេរកឃើញថា ខ្ញុំមានលក្ខណៈសម្បត្តិទទួលជំនួយប្រាក់ចំណូលសន្តិសុខបន្ថែម ហៅកាត់ថា SSI, ខ្ញុំយល់ថា ខ្ញុំទទួលអនុញ្ញាតឱយ គណៈកម្មការនៃការិយាល័យអភិបាលកិច្ចសន្តិសុខសង្គម (SSA) ផ្ញើ៖

- ប្រាក់បង់ជំនួយប្រតិសកម្ម SSI ទីមួយរបស់ខ្ញុំ ទៅឱយរដ្ឋ; ឬ
- បើច្បាប់សហព័ន្ធកំរិតនូវរបៀបដែលប្រាក់ SSI ត្រូវបង់មកឱយខ្ញុំនោះ, ចូរផ្ញើទៅឱយរដ្ឋតែចំនួនស្មើនឹងចំនួន ជំនួយប្រាក់សាធារណៈដែលអាចត្រូវសងវិញ ដែលខ្ញុំបានទទួលពីរដ្ឋ តែប៉ុណ្ណោះ ។

តើគេត្រូវបង់ទៅឱយរដ្ឋដោយរបៀបណា ចំពោះជំនួយប្រាក់សាធារណៈត្រូវសងវិញដែលរដ្ឋបានប្រគល់ដល់ខ្ញុំនោះ?

រដ្ឋនឹងដកយកចេញពីប្រាក់ប្រតិសកម្ម SSI ទីមួយរបស់ខ្ញុំ នូវចំនួនប្រាក់ស្មើនឹងចំនួនដែលខ្ញុំបានទទួលពីរដ្ឋ សំរាប់រយៈពេល ចាប់ផ្តើមពីខែទីមួយដែលខ្ញុំមានលក្ខណៈសម្បត្តិទទួលជំនួយប្រាក់ SSI ហើយចប់នៅក្នុងខែ ដែលប្រាក់ SSI របស់ខ្ញុំត្រូវចាប់ផ្តើម ។ បើរដ្ឋ មិនអាចបញ្ឈប់ជំនួយប្រាក់សាធារណៈរបស់ខ្ញុំភ្លាមៗទេ, រយៈពេលនោះនឹងត្រូវចប់ក្នុងខែបន្ទាប់ ។ បើច្បាប់សហព័ន្ធកំរិតកំណត់នូវរបៀបដែលខ្ញុំអាចទទួលប្រាក់ដែលលើសយ៉ាងណាក្តី, ការិយាល័យ SSA នឹងផ្ញើទៅឱយរដ្ឋតែចំនួនប្រាក់ស្មើនឹងចំនួនដែលខ្ញុំបានទទួលពីរដ្ឋតែប៉ុណ្ណោះ ។ រដ្ឋនឹងមិនដកយកពីប្រាក់ជំនួយណា ដែលផ្តល់ឱយខ្ញុំទាំងអស់ ឬភាគខ្លះ ដោយប្រាក់សហព័ន្ធនោះទេ ។

ចុះប្រសិនបើរដ្ឋបានទទួលប្រាក់ចំនួនច្រើនពេកនោះ?

រដ្ឋនឹងផ្ញើមកឱយខ្ញុំវិញនូវចំនួនប្រាក់លើសណាក្តី ដោយមានសំបុត្រមួយបញ្ជាក់ប្រាប់ខ្ញុំថាតើរដ្ឋបានដកទុកចំនួនប៉ុន្មាន ក្នុងរយៈពេល 10 ថ្ងៃធ្វើការ បន្ទាប់ពីរដ្ឋបានទទួលការប្រាក់ពីការិយាល័យ SSA ។

តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើការិយាល័យ SSA ផ្ញើការបង់ប្រាក់ទីមួយមកឱយខ្ញុំ?

ខ្ញុំនឹងចារនូវសែកប្រាក់ថា "payable to the State of Washington" ហើយផ្ញើវាទៅ៖

STATE OF WASHINGTON
OFFICE OF FINANCIAL RECOVERY (OFR), MAIL STOP 5862
PO BOX 9501
OLYMPIA WA 98507-9501

តើការអនុញ្ញាតយល់ព្រមនេះមានប្រសិទ្ធភាពយូរប៉ុន្មាន?

ការអនុញ្ញាតយល់ព្រមនេះមានប្រសិទ្ធភាពតាមច្បាប់រវាងរដ្ឋនិងខ្ញុំ សំរាប់រយៈពេលមួយឆ្នាំចាប់ពីថ្ងៃដែលរដ្ឋទទួលវាហើយ ។ ការអនុញ្ញាតយល់ព្រមនេះ ត្រូវតែមានចុះហត្ថលេខា និងកាលបរិច្ឆេទបញ្ជាក់ដោយអ្នកតំណាងរបស់រដ្ឋហើយនិងរូបខ្ញុំ ដើម្បីធ្វើឱយវាមានសុពលភាព ។ ការិយាល័យ SSA នឹងរក្សាទុកការអនុញ្ញាតយល់ព្រមនេះជាសំណុំឯកសារ រយៈពេលមួយឆ្នាំ ។

- ខ្ញុំទទួលប្រាក់ជំនួយ SSI ដំបូងទីមួយរបស់ខ្ញុំ; ឬ
- ខ្ញុំមិនបានដាក់ពាក្យស្នើសុំឱយពិនិត្យសាឡើងវិញទាន់ពេលវេលា ហើយរយៈពេលយូរបំផុតដែលគេអនុញ្ញាតឱយដាក់ពាក្យស្នើសុំការពិនិត្យសាឡើងវិញតាមផ្នែករដ្ឋបាល ឬតាមផ្នែកតុលារ ផុតអាណត្តិហើយ; ឬ
- រដ្ឋ ហើយនិងខ្ញុំយល់ព្រមបញ្ចប់ការអនុញ្ញាតយល់ព្រមនេះ ។

ការអនុញ្ញាតយល់ព្រមនេះមិនមានប្រសិទ្ធភាពតាមច្បាប់ចំពោះខ្ញុំទេ ប្រសិនបើរដ្ឋមិនបានឱយដំណឹងទៅការិយាល័យ SSA ថា ខ្ញុំបានចុះហត្ថលេខាលើការអនុញ្ញាតយល់ព្រមនេះ ក្នុងរយៈពេល 30 ថ្ងៃ ចាប់ពីថ្ងៃដែលខ្ញុំចុះហត្ថលេខាលើក្រដាសពាក្យនេះ ។

តើការអនុញ្ញាតយល់ព្រមនេះមានតួនាទីបំរើដាការដាក់ពាក្យការពារសំរាប់ជំនួយប្រាក់ SSI ឬទេ?

បាទ/ចា៎, ប្រសិនបើខ្ញុំមិនទាន់បានដាក់ពាក្យសុំ SSI នៅឡើយ ហើយខ្ញុំមានបំណងដាក់ពាក្យសុំជំនួយ SSI, ក្រដាសពាក្យនេះ គឺជាប្រវេសន៍ពីការិយាល័យ SSA ថា ខ្ញុំមានពេល 60 ថ្ងៃ ដើម្បីដាក់ពាក្យសុំជំនួយ SSI ដើម្បីការពារកាលបរិច្ឆេទដាក់ពាក្យសុំរបស់ខ្ញុំ ។ បើគេទទួលយល់ព្រមដល់ពាក្យដាក់សុំរបស់ខ្ញុំ, ជំនួយប្រាក់ SSI របស់ខ្ញុំ អាចមានប្រសិទ្ធភាព ចាប់ពីថ្ងៃដែលខ្ញុំចុះហត្ថលេខាលើក្រដាសពាក្យនេះ ។ បើខ្ញុំមិនដាក់ពាក្យសុំជំនួយប្រាក់ SSI ក្នុងរយៈពេល 60 ថ្ងៃទេនោះ, ការអនុញ្ញាតយល់ព្រមនេះ ឈប់ការពារកាលបរិច្ឆេទដាក់ពាក្យសុំរបស់ខ្ញុំទៀតហើយ ។

ខ្ញុំមានសិទ្ធិទទួលនូវសវនាការដ៏យុត្តិធម៌មួយ បើសិនជាខ្ញុំមិនយល់ស្រុបជាមួយនឹងអំពើណាមួយដែលធ្វើឡើងដោយរដ្ឋ ដែលទាក់ទងនឹងការអនុញ្ញាតយល់ព្រមនេះ ហើយនិងការសងប្រាក់វិញ។

ហត្ថលេខារបស់អតិថិជន	ខែ/ថ្ងៃ/ឆ្នាំ
ហត្ថលេខារបស់អ្នកតំណាងរដ្ឋ	ខែ/ថ្ងៃ/ឆ្នាំ ដែលបានទទួលដោយ DSHS